មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

**រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០**

**សម្រាប់ការផ្សព្វផ្សាយជាបន្ទាន់**

---

## ការផ្តន្ទាទោស បង្ហាញថា រដ្ឋាភិបាលប៉ុនប៉ងរុញច្រានលោកសម រង្ស៊ី ពីឆាកនយោបាយ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ថ្កោលទោសចំពោះសាលក្រមដែលមានលក្ខណៈនយោបាយ ចេញនៅថ្ងៃនេះដោយសាលាដំបូងរាជធានីភ្នំពេញ ដែលបានរកឃើញថា លោកសម រង្ស៊ី មេដឹកនាំគណបក្សប្រឆាំងនៃប្រទេសកម្ពុជា មានពិរុទ្ធភាព ពីបទក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ និងបទផ្សាយព័ត៌មានមិនពិត។ សាលក្រមនេះបានបង្ហាញភស្តុតាងថា តុលាការកម្ពុជាត្រូវបានប្រើប្រាស់ជាឧបករណ៍នយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីធ្វើឱ្យបាត់តម្លៃនូវភាពត្រឹមត្រូវស្របច្បាប់របស់គណបក្សនយោបាយប្រឆាំង។ ការណ៍នេះបង្ហាញថា ការប្រើប្រាស់តុលាការមិនត្រឹមត្រូវ អាចនាំឱ្យបញ្ចប់អាជីពអ្នកនយោបាយកម្ពុជាដ៏មានប្រជាប្រិយភាពម្នាក់។

បទចោទប្រកាន់បានអះអាងថា លោកសម រង្ស៊ីបានកែប្រែផែនទីកម្ពុជានៅអង្គការសហប្រជាជាតិ ដោយក្លែងបន្លំអំពីការទន្ទ្រានចូលដីកម្ពុជាពីសំណាក់ប្រទេសវៀតណាម ហើយបន្ទាប់មកបានដាក់ផែនទីនោះនៅលើវេបសាយរបស់គណបក្សសមរង្ស៊ី។ ប៉ុន្តែ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាកត់សម្គាល់ឃើញថា មានតែភស្តុតាងជាឯកសារ និងសក្ខីភាពបន្តិចបន្តួចប៉ុណ្ណោះត្រូវបានបង្ហាញនៅក្នុងសវនាការ ដើម្បីគាំទ្របទចោទប្រកាន់នេះ។ លោកសម រង្ស៊ីដែលត្រូវបានកាត់ទោសកំបាំងមុខ ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារ ១០ឆ្នាំ និងផាកពិន័យ ៥ លានរៀល ព្រមទាំងបង់ ៦០ លានរៀល ជាសំណងជំងឺចិត្តទៅឱ្យរាជរដ្ឋាភិបាលកម្ពុជា ពីបទក្លែងបន្លំអក្សរក្នុងឯកសារសាធារណៈ និងផ្សាយព័ត៌មានមិនពិត។ សាលក្រមដែលខ្វះមូលដ្ឋានច្បាប់ និងភាពធ្ងន់ធ្ងរនៃទោស បានបញ្ជាក់ថា សវនាការមានលក្ខណៈនយោបាយ និងបានផ្ញើសារយ៉ាងច្បាស់ដល់តំណាងរាស្ត្រគណបក្សប្រឆាំង និងអ្នកឯទៀត ដែលចង់សាកសួរអំពីគោលនយោបាយ និងសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជា។

ការផ្តន្ទាទោសនៅថ្ងៃនេះ គឺជាវិធានការណ៍តុលាការដែលមានលក្ខណៈនយោបាយមួយទៀត បន្ទាប់វិធានការណ៍ជាច្រើនប្រឆាំងនឹងលោកសម រង្ស៊ី។ នៅខែមករា លោកសម រង្ស៊ី ត្រូវបានផ្តន្ទាទោសពីបទផ្សាយព័ត៌មានមិនពិត និងញុះញង់ឱ្យមានការរើសអើងពូជសាសន៍ ហើយបើយោងតាមសារព័ត៌មានភ្នំពេញប៉ុស្ត៍ចេញផ្សាយកាលពីថ្ងៃអង្គារ តុលាការបានកោះហៅលោកសម រង្ស៊ី ទាក់ទងនឹងពាក្យបណ្តឹងរបស់ឯកឧត្តមហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស ដែលបានប្តឹងលោកសម រង្ស៊ីពីបទបរិហាកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិត កាលពី ២ឆ្នាំមុន។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា អំពាវនាវឱ្យរាជរដ្ឋាភិបាលកម្ពុជាបញ្ចប់ការប្រើតុលាការជាឧបករណ៍នយោបាយ ដើម្បីវាយប្រហារគណបក្សប្រឆាំង និងបិទមាត់មតិយោបល់ដែលផ្ទុយពីខ្លួន។ ប្រទេសកម្ពុជាត្រូវការគណបក្សប្រឆាំងសកម្ម ដើម្បីបង្កើតលទ្ធិប្រជាធិបតេយ្យមួយដែលខ្លាំង មានស្ថេរភាព និងពហុបក្ស ព្រមទាំងតុលាការមួយដែលឯករាជ្យ និងមិនលំអៀង ដើម្បីលើកកម្ពស់នីតិរដ្ឋ។


សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក អ៊ូ វីរៈ** ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

លេខទូរស័ព្ទ ៖ +៨៥៥ ១២ ៤០ ៤០ ៥១

អ៊ីមែល ៖ ouvirak@cchrcambodia.org